**សលាកប័ត្រព័ត៌មាន ៖ កម្រងឯកសារស្តីពីស្ថាប័ន ៖ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ស្ថាប័ន ៖** អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)

**រូបភាពរួម ៖** អ.វ.ត.ក ត្រូវបានបង្កើតឡើងដើម្បីជំនុំជម្រះទោសជនដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះបទឧក្រិដ្ឋដែលបានប្រព្រឹត្តិនៅប្រទេសកម្ពុជាក្នុងសម័យខ្មែរក្រហមដោយអនុឡោមតាមច្បាប់អន្តរជាតិ និងច្បាប់កម្ពុជា ។ តុលាការ "កូនកាត់" រួមផ្សំដោយបុគ្គលិកជាតិ និងអន្តរជាតិ អ.វ.ត.ក ត្រូវបានគំរាមកំហែងដោយរឿងចម្រូងចម្រាស និងបញ្ហាប្រឈមដោយបន្សល់ជាកេរ្តិ៍ដំណែលបរាជ័យក្នុងប្រព័ន្ធតុលាការកម្ពុជា ។

## សេចក្តីផ្តើម

សលាកបត្រនេះពណ៌នាអំពីទិដ្ឋភាពទូទៅនៃ អ.វ.ត.ក លើក្របខណ្ឌច្បាប់ និង រឿងចម្រូងចម្រាសនាពេលថ្មីៗនេះដែលក្នុងនោះរួមមានការចោទប្រកាន់អំពីការជ្រៀតជ្រែកនយោបាយផងដែរ ។ សលាកបត្រនេះក៏ផ្តល់នូវអនុសាសន៍ដែលពិចារណាអំពីកេរ្តិ៍ដំណែលដែលស្ថាប័ននេះនឹងបន្សល់ទុកសំរាប់តុលាការ និង នីតិរដ្ឋនៅប្រទេសកម្ពុជា ។ សលាកប័ត្រនេះត្រូវបានតាក់តែងឡើងដោយ ម.ស.ម.ក ដែលជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ និងមិនចូលបក្សសម្ព័ន្ធ ធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងគោរពសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ នៅប្រទេសកម្ពុជា ។

## អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

អ.វ.ត.ក ជាតុលាការកម្ពុជាដែលទទួលបានការគាំទ្រពីអង្គការសហប្រជាជាតិ (អ.ស.ប) ត្រូវបានបង្កើតឡើងដើម្បីជំនុំជម្រះជនទាំងឡាយណាដែលជាអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងប្រជាជនកម្ពុជាក្នុងសម័យកម្ពុជាប្រជាធិបតេយ្យដោយរដ្ឋាភិបាលខ្មែរក្រហមចន្លោះពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩ ។ យុត្តាធិការបុគ្គល អ.វ.ត.ក កំណត់ត្រឹមតែ មេដឹកនាំជាន់ខ្ពស់នៃកម្ពុជាប្រជាធិបតេយ្យ និង បុគ្គលដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម ។ បទចោទក្នុងយុត្តាធិការរបស់ អ.វ.ត.ក មានដូចជា អំពើមនុស្សឃាដ ការធ្វើទារុណកម្ម និង ការធ្វើទុក្ខបុកម្នេញខាងសាសនា នៅក្រោមបញ្ញាត្តិនៃក្រមព្រហ្មទណ្ឌរបស់កម្ពុជាឆ្នាំ ១៩៥៦ និងបទឧក្រិដ្ឋនៅក្រោមច្បាប់របស់អន្តរជាតិ រួមមាន អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩៤៩ ការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិវប្បធម៌កំឡុងពេលមានជម្លោះប្រដាប់អាវុធ និងឧក្រិដ្ឋកម្មប្រឆាំងមន្ត្រីទូតដែលត្រូវបានការពារក្រោមអនុសញ្ញាទីក្រុងវៀន ឆ្នាំ ១៩៦១ ។

បន្ថែមពីលើការអនុវត្តទាំងច្បាប់ជាតិ និង អន្តរជាតិ ក៏មានទិដ្ឋភាពសំខាន់មួយទៀតក្នុងតុលាការ "កូនកាត់" នៃ អ.វ.ត.ក គឺ តុលាការនេះមាន ចៅក្រម ព្រះរាជអាជ្ញា និង មេធាវីការពារក្តី ចម្រុះជាតិ និង អន្តរជាតិ ។ ខុសពីតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និង តុលាការឧក្រិដ្ឋកម្មអន្តរជាតិសំរាប់ប្រទេសរ្វ៉ាន់ដា អ.វ.ត.ក មានទីតាំងក្នុងប្រទេសដែលឧក្រិដ្ឋកម្មបានកើតឡើង ក្នុងគោលបំណងដើម្បីលើកទឹកចិត្តប្រជាជនកម្ពុជាចូលរួមឲ្យបានពេញលេញក្នុងតុលាការ និង ផ្តល់ឲ្យតុលាការកម្ពុជានូវតុល្យភាព និង ធម្មានុរូបក្នុងក្របខ័ណ្ឌដើម្បីជាគំរូនៃប្រព័ន្ធតុលាការជាតិ ។ ជនរងគ្រោះមានលទ្ធភាពចូលរួមក្នុងសវនាការ និង អាចដាក់ពាក្យបណ្តឹងនៅការិយាល័យសហព្រះរាជអាជ្ញា ចំពោះបទឧក្រិដ្ឋកម្មដែលខ្លួនបានរងគ្រោះ ឬ អាចតាំងខ្លួនជាភាគីរដ្ឋប្បវេណី ដែលអាចឲ្យពួកគេទាមទារជាសំណងរួម និង សំណងសីលធម៌ ។ បន្ថែមពីលើរាជរដ្ឋាភិបាលកម្ពុជា (រ.រ.ក) មានប្រទេសម្ចាស់ជំនួយសំខាន់ៗ ដូចជា ជប៉ុន បារាំង អាឡឺម៉ង់ អូស្រ្តាលី សហរដ្ឋអាមេរិក ចក្រភពអង់គ្លេស និង សហភាពអឺរ៉ុប ។

## សំណុំរឿងនៅ អ.វ.ត.ក

បច្ចុប្បន្ន អ.វ.ត.ក កំពុងធ្វើការជំនុំជម្រះលើជនជាប់ចោទចំនួន ០៣ រូបទៀតនៃសំណុំរឿង ០០២ រួមមាន លោក នួន ជា លោក ខៀវ សំផន និង លោក អៀង សារី ចំពោះអំពើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ និង អំពើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ។ ជនជាប់ចោទទី ០៤ ឈ្មោះ អៀង ធិរិទ្ធ ត្រូវបានរកឃើញថាមានកាយសម្បទាមិនគ្រប់គ្រាន់សំរាប់ការជំនុំជម្រះទោសដោយហេតុតែបញ្ហាស្មារតី និង ត្រូវបានបំបែក

ចេញពីរឿងក្តីបើទោះបីជាករណីនេះត្រូវបានត្រួតពិនិត្យឡើងវិញក្នុងឆ្នាំ ២០១២ ។ សេចក្តីថ្លែងការណ៍បើកត្រូវបានធ្វើឡើងក្នុងខែវិច្ឆិកា ឆ្នាំ ២០១១ ។ សំណុំរឿងត្រូវបានបំបែកទៅជា "សវនាការតូច" លើបញ្ហាចោទដាច់ដោយឡែកពីគ្នា ។ បច្ចុប្បន្ននេះ អ.វ.ត.ក កំពុងធ្វើសវនាការករណីសវនាការតូចដំបូងស្តីពីការជន្លៀសប្រជាជនដោយបង្ខំក្នុងឆ្នាំ ១៩៧៥ ។

សហព្រះរាជអាជ្ញាអន្តរជាតិបានចេញដីកាបញ្ជូនរឿងឲ្យស៊ើបសួរលើសំណុំរឿងពីរបន្ថែមទៀតគឺ សំណុំរឿង ០០៣ និង០០៤ ដែលមានជនសង្ស័យបន្ថែមចំនួន ០៥ នាក់ទៀត ។ ក្នុងរយៈពេលថ្មីៗនេះ សំណុំរឿងទាំងពីរស្ថិតនៅក្នុងដំណាក់កាលចៅក្រមស៊ើបអង្កេត និង បានក្លាយជាកម្មវត្ថុនៃរឿងចម្រូងចម្រាស ។

## រឿងចម្រូងចម្រាសនាពេលថ្មីៗ

ទោះជាសេចក្តីសន្និដ្ឋាននៃសំណុំរឿងទី ១ បានផ្តន្ទាទោសឌុច ក្តី មានការចោទប្រកាន់ស្តីពីអំពើពុករលួយ និង ការជ្រៀតជ្រែកនយោបាយនៅតែបន្តលើកិច្ចការរបស់តុលាការ ។ កាលពីខែ មិនា ឆ្នាំ ២០១២ សហចៅក្រមស៊ើបអង្កេតបំរុងអន្តរជាតិ ឡូរ៉ង់ កាប៉ឺ អានសឺម៉េត បានសម្រេចលាឈប់ពី អ.វ.ត.ក ដោយមូលហេតុអសមត្ថភាពដើម្បី "អនុវត្តន៍មុខងារសមស្របតាមផ្លូវច្បាប់ និង សេរីរបស់គាត់" ព្រោះមានការជ្រៀតជ្រែកនយោបាយ ។ ការលាឈប់របស់ចៅក្រម ឡូរ៉ង់ កាប៉ឺ អានសឺម៉េត គឺដោយសារតែមានការជំទាស់យ៉ាងធ្ងន់ធ្ងរជុំវិញកិច្ចស៊ើបអង្កេតលើសំណុំរឿង ០០៣ និង ០០៤ ដោយសហចៅក្រមស៊ើបអង្កេតជាតិ យូ ប៊ុនឡេង ដែលចៅក្រម កាប៉ឺ អានសឺម៉េត អះអាងថាបាននាំដល់ "ស្ថានការណ៍នៃភាពមិនអាចដំណើរការបាននៅក្នុង អ.វ.ត.ក" ។ ចៅក្រម យូ ប៊ុនឡេង បដិសេធនូវសិទ្ធិអំណាចរបស់ចៅក្រម ឡូរ៉ង់ កាប៉ឺ អានសឺម៉េត ធ្វើសកម្មភាពក្នុងសមត្ថភាពរបស់លោកជាសហចៅក្រមស៊ើបអង្កេតបំរុងអន្តរជាតិទោះបីជាមុនពេលលោកមកដល់ប្រទេសកម្ពុជាក្តី និង ជាពិសេស នៅពេលដែលឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមបដិសេធការតែងតាំងលោកជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិដោយបញ្ចប់សកម្មភាពចៅក្រម កាប៉ឺ អានសឺម៉េតលើចំណាត់ការស៊ើបអង្កេតសំខាន់ៗ ឬ កិច្ចគតិយុត្តក្នុងសំណុំរឿង ០០៣ និង ០០៤ ។

## សេចក្តីសន្និដ្ឋាន និង អនុសាសន៍

ការលាលែងរបស់ចៅក្រម ឡូរ៉ង់ កាប៉ឺ អានសឺម៉េត គឺជាព្រឹត្តិការណ៍ចម្រូងចម្រាសចុងក្រោយនៅក្នុងតុលាការដែលគំរាមកំហែងដល់ការប្តេជ្ញាផ្តល់យុត្តិធម៌ដល់ជនរងគ្រោះនៃរបបខ្មែរក្រហម ។ ដោយសារតែប្រព័ន្ធយុត្តិធម៌កម្ពុជាដែលខ្វះឯករាជ្យភាព និង ជាទំលាប់រំលោភលើសិទ្ធិជំនុំជម្រះដោយយុត្តិធម៌ អ.វ.ត.ក មានឥទ្ធិពលសំរាប់ជាមរតកដល់ប្រព័ន្ធតុលាការកម្ពុជានូវយុត្តិធម៌ក្នុងបទដ្ឋានអន្តរជាតិ ។ ការជ្រៀតជ្រែកក្នុងកិច្ចដំណើរការនីតិវិធី អ.វ.ត.កដោយរដ្ឋាភិបាលកម្ពុជា បានគំរាមកំហែងដល់សក្តានុពលនៃកេរ្តិ៍ដំណែលនេះ ។ រដ្ឋាភិបាលកម្ពុជាត្រូវកំហិតរាល់រូបភាពនៃការជ្រៀតជ្រែកលើដំណើរការរបស់ អ.វ.ត.ក ។ បើមិនដូច្នេះទេ អាចបង្កឲ្យមានការចោទសួរអំពីតួនាទីរបស់តុលាការ និង ធ្វើឲ្យខូចសាលក្រមតុលាការនៅក្នុងក្រសែភ្នែកសង្គមអន្តរជាតិទូទៅ និង ជាពិសេសគឺជនរងគ្រោះ ។

អង្គការសហប្រជាជាតិត្រូវចាត់ការស៊ើបអង្កេតលើការជ្រៀតជ្រែកនយោបាយនៅ អ.វ.ត.ក មិនមែនត្រឹមតែក្នុងសំណុំរឿង ០០៣ និង ០០៤ ទេប៉ុន្តែគឺត្រូវស៊ើបអង្កេតលើរាល់ដំណើរការ ។ អាស្រ័យលើការស្រាវជ្រាវទាំងឡាយ អង្គការសហប្រជាជាតិត្រូវពិចារណាឲ្យបានម្មត់ចត់អំពីតួនាទីរបស់ខ្លួននៅក្នុងតុលាការ ដោយរួមទាំងការបដិសេធផ្តល់ជំនួយដល់តុលាការប្រសិនបើចាំបាច់ ។ ប្រសិនអង្គការសហប្រជាជាតិខកខានក្នុងការចាត់វិធានការដោះស្រាយបញ្ហាអន្តរាយស្ថាប័នដោយមូលហេតុនៃការជ្រៀតជ្រែកនយោបាយទេ សុចរិតភាពនៃ អ.វ.ត.ក នឹងត្រូវប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង លោក អ៊ូ វីរៈ (+៨៥៥ (0) ១២ ៤០ ៤០ ៥១ ឬអ៊ីម៉ែលៈ ouvirak@cchrcambodia.org
ឬ កញ្ញា ហ្សូលីយ៉ែត រ៉ូហ្សេឡូត (+៨៥៥ (0) ១៥ ៣៥ ០៦ ២០ ឬអ៊ីម៉ែលៈ juliettrousselot@cchrcambodia.org ។

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights
BY NC SF